# អង្គរបុរី
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ
## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ រាជរដ្ឋាភិបាលខ្មែរបញ្ជូនប្រជាពលរដ្ឋ
## របស់ខ្លួនទៅឲ្យបរទេសកាត់ទោស

website: www.hoksavann.org

ថ្ងៃទី១០ សីហា ២០០៧



រដ្ឋធម្មនុញ្ញនៃរាជាណាចក្រកម្ពុជា ត្រង់មាត្រាពពជំពូកទីពចែងថា ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ។ បញ្ហាព្រះសង្ឃទីម-សាខន ឥឡូវនេះបានជាប់ឃុំនៅប្រទេសវៀត-ណាម បើតាមបណ្តាញព័ត៌មានវៀតណាម ដែលបានផ្សាយដោយចោទថា ព្រះភិក្ខុទីម-សាខនបានចូលទៅប្រទេសវៀតណាមដោយខុសច្បាប់ ហើយធ្វើឲ្យខូចមិត្តភាពកម្ពុជាវៀតណាម ។ អ្នកនាំពាក្យរាជរដ្ឋាភិបាល និងអ្នកនាំពាក្យក្រសួងមហាផ្ទៃនិយាយផ្ទុយគ្នា អំពីបញ្ហាបាត់ខ្លួនព្រះភិក្ខុទីម-សាខននេះ ។ ប៉ុន្តែបើតាមព័ត៌មានវៀតណាមនេះបញ្ជាក់ថា អ្នកនាំពាក្យក្រសួងមហាផ្ទៃនិយាយការពិត ប៉ុន្តែបានកែមូលហេតុនៃការធ្វើដំណើររបស់ព្រះភិក្ខុអង្គនេះ គឺលោកខៀវ-សុភ័គបាននិយាយថា អន្ទិតទីម-សាខន បន្ទាប់ពីបានសឹក ហើយបានបញ្ជូនទៅប្រទេសវៀតណាម តាមសំណូមពររបស់សាមីខ្លួន ថែមទាំងបានបង្ហាញឯកសារជាភស្តុតាងទៀតផង ។ ដូច្នេះបញ្ជាក់ថា រាជរដ្ឋាភិបាលខ្មែរបានទទួលសារភាពថា បានបញ្ជូនព្រះភិក្ខុទីម-សាខន ឲ្យបរទេសកាត់ទោសមែន ។ ត្រង់មូលហេតុថា អាជ្ញាធរខ្មែរធ្វើតាមសំណូមពររបស់សាមីខ្លួននោះ គ្មាននរ-ណាជឿឡើយ ព្រោះចោទភិក្ខុទីម-សាខនថា ធ្វើសកម្មភាពឲ្យខូចមិត្តភាពកម្ពុជា-វៀតណាម ដូច្នេះភិក្ខុទីម-សាខន មិនល្ងង់ដល់ថ្នាក់រត់ចូលគុកដូច្នេះឡើយ ។ ញាតិញោមរបស់ព្រះភិក្ខុទីម-សាខនទាំងអស់នៅភ្នំដិនប្រទេសកម្ពុជា ហើយលោកធ្វើជាចៅអធិការកសាងវត្តជាង២០ឆ្នាំមកហើយ ហើយត្រូវការអីទៅរស់នៅប្រទេសវៀតណាមឲ្យបែកញាតិញោម ។ បើតាមសាក្សីគេឃើញថា បន្ទាប់ពីព្រះភិក្ខុទីម-សាខនត្រូវគេចាប់ផ្សឹកដោ

24/06/2007

**HĐTSTW PHẬT GIÁO KPC**
**Số: 502/07-ĐN**

**VƯƠNG QUỐC KAMPUCHIA**
**Dân tộc - Tôn giáo - Quốc vương**

*Thủ đô Phnôm Pênh, ngày 16 tháng 06 năm 2007.*

*<u>Kính gửi</u>: Đại Tăng thống Tếp Vông - Vua sãi Vương quốc Kampuchia kính mến!*

Nội dung: Đề nghị cho xuất tu đối với Tỳ kheo Tưm Xà Khon - trụ trì chùa Phnum Đân Bắc/KiRiVong/Tà Keo.

Căn cứ nội dung trên, kính trình Đại Tăng thống Tếp Vông, Vua sãi Vương quốc Kampuchia rõ: Tùy kheo Tưm Xà Khon có hành động sai trái vi phạm giáo luật, gây chia rẽ tình đoàn kết dân tộc và quốc tế, đặc biệt giữa hai nước Kampuchia - Việt Nam, đã sử dụng chùa này làm Sở Chỉ huy để phục vụ hoạt động tuyên truyền làm ảnh hưởng đến giáo luật cao quý của Phật giáo.

Như nội dung đã trình bày trên, xin Đại Tăng thống chấp thuận cho nhà sư này hoàn tục./.

**Đã xem và thống nhất**
**Phnôm Pênh, ngày 17 tháng 06 năm 2007**

*(đã ký và đóng dấu)*

**TEP VÔNG**

**CHỦ TỊCH HỘI ĐỒNG TRỊ SỰ**

*(đã ký và đóng dấu)*

**NUÔN NGÉT**

*សូមពិនិត្យមើលសាភាចររបស់ព្រះមហាសុមេធាធិបតី នន្ទ-ង៉ែត ផ្ញើទៅសម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតីទេព-វង្ស បានសរសេរបកប្រែជាភាសាយួន ។ វត្ថុបំណង គឺគេមានចេតនាចាប់បញ្ជូនខ្លួនព្រះភិក្ខុទឹម-សាខន ទៅឲ្យយួនធ្វើទារុណកម្ម ដើម្បីឲ្យបាក់បកខ្ទបខ្ទាច លែងហ៊ានងើបឡើងការពារសិទ្ធិរបស់ខ្លួនតទៅទៀត ។ តើនេះហើយឬ ការវង្វេងសាច់ឈាមខ្លួនឯងរបស់ខ្មែរ សំរាប់គ្រាន់តែយកចិត្តចៅហ្វាយ និងដឹងគុណចៅហ្វាយ ដែលបានផ្ដល់អំណាចដល់ខ្លួន (??) ។*



យបង្ខំតាមបញ្ជារបស់សម្តេចសង្ឃនាយក និងសម្តេចសង្ឃរាជមក ព្រះភិក្ខុទឹម-សាខន បានត្រូវអង្គរក្សនាយករដ្ឋមន្ត្រី ចាប់បញ្ចូលក្នុងឡាននាំយកទៅបាត់ទៅ ។ ដោយមានប្រតិកម្មជាអន្តរជាតិ ទើបប្រឌិតភស្តុតាងថា សាមីខ្លួនទៅដោយស្ម័គ្រចិត្ត ។ ដោយមានគេចោទជុំទិស សម្តេចទេព-វង្សក៏ខំរកវិធីដោះសារដែរថា ការបញ្ជាឲ្យផ្សឹកនេះ ដោយសារតែភិក្ខុទឹម-សាខនទាក់ទងនឹងស្រីញី ហើយមាននីដេអូអាសអាភាស ដែលផ្ទុយគ្នាពីសា

រាចរមុនថា ភិក្ខុទឹម-សាខនធ្វើសកម្មភាពឲ្យខូចមិត្តភាពកម្ពុជា-វៀតណាម មិនឃើញចោទពីស្រីញីនោះឡើយ ។ ដូច្នេះបញ្ជាក់ថា ម្តងចោទបែបនេះ ម្តងចោទបែបនោះ ដើម្បីឲ្យមានទម្ងន់ កុំឲ្យគេចោទថា ផ្សឹកខុសធម៌ខុសវិន័យ ។ ចំណែកវៀតណាមវិញ ដែលថាចាប់ភិក្ខុទឹម-សាខន ដោយសារតែភិក្ខុអង្គនេះចូលប្រទេសវៀតណាមដោយខុសច្បាប់នោះ គ្រាន់តែជាលេសជួយបិទបាំងសកម្មភាពរបស់រាជរដ្ឋាភិបាល ដែលបញ្ជូនប្រជាពលរដ្ឋរបស់ខ្លួនឲ្យបរទេសកាត់ទោស ។

សរុបសេចក្តីមក ព្រឹត្តិការណ៍ទាំងអស់កើតពីបំណងរបស់វៀតណាម ចង់បំបាក់ស្មារតីខ្មែរកម្ពុជាក្រោម មិនឲ្យក្រោកឡើងទាមទារសិទ្ធិសេរីភាពស្របតាមច្បាប់ជាតិ និងច្បាប់អង្គការសហប្រជាជាតិ ដូច្នេះហើយបានជាគេចាប់ផ្សឹក ហើយដាក់គុកព្រះសង្ឃនៅកម្ពុជាក្រោម ហើយបញ្ជាឲ្យរាជរដ្ឋាភិបាលនិងសម្តេចសង្ឃខ្មែរ ចាប់ផ្សឹកព្រះសង្ឃខ្មែរណាដែលគេចុចឈ្មោះ ហើយបញ្ជូនឲ្យគេកាត់ទោស ព្រោះយើងឃើញថា បន្ទាប់ពីភិក្ខុទឹម-សាខននៅក្នុងកណ្តាប់ដៃហើយ វៀតណាមក៏ចាប់ចោទភិក្ខុទឹម-សាខនជាបទព្រហ្មទណ្ឌ ដូចសារាចររបស់សម្តេចសង្ឃទាំងពីរជាភាសាខ្មែរនិងភាសាវៀតណាម ពុំមែនចោទយកជាលេសត្រឹមតែទឹម-សាខនចូលប្រទេសវៀតណាមដោយខុសច្បាប់នោះឡើយ ។ ព្រះសង្ឃនិងគ្រហស្ថខ្មែរកម្ពុជាក្រោមដទៃទៀត ដែលជាមុខសញ្ញាដែលវៀតណាមត្រូវកំចាត់ទំនងជាផ្អាកជាបណ្តោះអាសន្នសិន ដោយសារប្រតិកម្មដ៏ខ្លាំងក្លាពីមតិជាតិនិងអន្តរជាតិ ទំនងជារកមធ្យោបាយផ្សេងពីនេះ ។ ហេតុការណ៍កន្លងមកនេះបញ្ជាក់ថា ប្រទេសកម្ពុជានៅក្រោមអំណាចវៀតណាម ។ ចាប់ពីឆ្នាំ១៩៨៩ គឺពេលដែលវៀតណាមប្រកាសដកទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា វៀតណាមបានរៀបចំជើងព្រួល គឺភ្នាក់ងាររបស់គេបង្កប់ខ្លួន សំរាប់បញ្ជាលើបក្សប្រជាជនកម្ពុជាស្ទើរគ្រប់ក្រសួង ជាពិសេសក្រសួងធំៗបី គឺក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងទីស្តីការនាយករដ្ឋមន្ត្រី ។ បញ្ហាអ្វីមួយដែលវៀតណាមបញ្ជា បក្សប្រជាជនតែងតែធ្វើឲ្យបានសំរេច ដូចជាសន្ធិសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាខុសច្បាប់ឆ្នាំ១៩៨៥ជាដើម ។

នេះជាគ្រោះថ្នាក់ធំណាស់សំរាប់ប្រទេសកម្ពុជា ដែលមានបរទេសបញ្ជាពីលើ ។ នៅប្រទេសលាវ ត្រូវវៀតណាមត្រួតត្រាគ្រប់ក្រសួងដោយចេញមុខ ។ ចំណែកនៅកម្ពុជា ត្រូវវៀតណាមត្រួតត្រាក្រសួងធំៗដូចបានពោលខាងលើ ប៉ុន្តែដោយលាក់មុខ ។ បើពត៌មានដែលថាវៀតណាមនៅតែមានអំណាចលើស្ថាប័នធំៗរបស់ខ្មែរ គឺមុននឹងសំរេចលើបញ្ហាសំខាន់ៗរបស់ជាតិខ្មែរ ត្រូវមានការយល់ព្រមពីវៀតណាមសិននោះជាការពុំពិតក៏ទុកពាក្យនេះជាអាសារឥតការទៅចុះ សូមកុំឲ្យមានបាប ។ ប៉ុន្តែពត៌មានជាអាថ៌កំបាំងនេះ ជាពត៌មានសំខាន់សំរាប់ប្រជាពលរដ្ឋខ្មែរពិចារណា ហើយស្រាវជ្រាវរកការពិតដើម្បីការរស់រានមានជីវិតនៃប្រទេសកម្ពុជា ។ បើពត៌មាននេះជាការពិតវិញនោះ ជាគ្រោះថ្នា

ក់ធំណាស់របស់ប្រទេសកម្ពុជាទៅអនាគត ។ បើគណបក្សប្រជាជនកម្ពុជាដកខ្លួនចេញពីអំណាចវៀតណាមបាន នោះជាជោគជ័យធំណាស់សំរាប់គណបក្សនេះ ហើយក៏ធ្វើឲ្យប្រទេសកម្ពុជាចេញផុតពីគ្រោះថ្នាក់ ពីឥទ្ធិពលវៀតណាមដែរ ។

តាមទស្សនៈរបស់សាស្ត្រាចារ្យម្នាក់និយាយថា មិនដល់មួយសតវត្សរ៍ទៀតទេ ព្រំប្រទល់ដែនប្រទេសថៃនិងជាប់គ្នាជាមួយប្រទេសវៀតណាម ។ បានសេចក្តីថា មិនមានប្រទេសកម្ពុជានៅលើផែនទីពិភពលោកទៀតទេ ។ យើងមានការបារម្ភអំពីអភិវឌ្ឍន៍ត្រីកោណ រវាងប្រទេសទាំងបីកម្ពុជា លាវ និងវៀតណាម ដែលខាងខ្មែរដាក់ខេត្តបីគឺ ខេត្តរតនគីរី ខេត្តមណ្ឌលគីរី និងខេត្តក្រចេះ ដែលមានសម្បត្តិធម្មជាតិដ៏ច្រើន ហើយមានពលរដ្ឋខ្មែរតិច ចំណែកខេត្តខាងប្រទេសទាំងពីរ មានប្រជាជនច្រើន គឺការអភិវឌ្ឍន៍នេះ សំរាប់ចិញ្ចឹមប្រជាជនគេប៉ុណ្ណោះ ហើយជាការឈានទៅរកសហព័ន្ធឥណ្ឌូចិន តាមផែនការរបស់ខ្មោចហូ-ជីមិញផង ។

បែរមកនិយាយអំពីបញ្ហាភិក្ខុទីម-សាខនវិញ បើរាជរដ្ឋាភិបាលខ្មែរចរចាជាមួយវៀតណាមយកភិក្ខុអង្គនេះមកប្រទេសកម្ពុជា ហើយឲ្យធ្វើជាចៅអធិការដូចដើមវិញ បើសឹកហើយត្រូវបំបួសឡើងវិញ នោះជាដំណោះស្រាយត្រឹមត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធសាសនាផង និងត្រឹមត្រូវតាមផ្លូវអាណាចក្រផង ។

បញ្ហាដ៏ធ្ងន់មួយទៀត ក្នុងពេលថ្មីៗនេះ ព្រះភិក្ខុអឿន-សុខធឿនជាព្រះសង្ឃខ្មែរកម្ពុជាក្រោមព្រះជន្ម៣០វស្សាបានត្រូវជនមិនស្គាល់មុខលួចធ្វើគត់ដោយអាវុធព្រះសុរង នៅវត្តទ្រនំជ្រឹង ស្រុកអង្គស្នួល ខេត្តកណ្តាលប្រទេសកម្ពុជា ក្រោយពេលធ្វើបាតុកម្ម យកញាតិទៅឲ្យទូតយួននៅភ្នំពេញ ទន្ទឹមគ្នានឹងប្រធានាធិបតីយួនមកធ្វើទស្សនកិច្ចនៅប្រទេ-សកម្ពុជា ។ អាជ្ញាធរខ្មែរបាននិយាយថា ព្រះភិក្ខុអឿន-សុខធឿនត្រូវសុគតដោយធ្វើអត្តឃាតខ្លួនលោក ។ អ្នកសង្កេតការណ៍ទូទៅមិនយល់ស្របតាមការនិយាយរបស់អាជ្ញាធរខ្មែរឡើយ ព្រោះស្នាមអាវុធមានពីក្រោយផង ហើយភស្តុតាងដ៏សំខាន់មួយទៀត ត្រង់សកម្មភាពអាជ្ញាធរខ្មែរមិនព្រមឲ្យគេធ្វើកោសល្យវិច័យ ស្រាប់តែយកទៅកប់ គឺសុគតនៅម៉ោង៩ យកទៅកប់នៅម៉ោង១០យប់ ហើយព្រះសង្ឃនិងឧបាសកឧបាសិកាទៅបង្សុកូលនៅកន្លែងកប់នោះតែម្តង តែត្រូវរារាំងដោយអាជ្ញាធរខ្មែរ ទើបគេសង្ស័យថាអំពើឃាតកម្មនេះ ជាអំពើគិតទុកជាមុនរបស់អាជ្ញាធរខ្មែរជាមួយចារកិច្ចយួន ហើយភស្តុតាងមួយទៀតអាជ្ញាធរខ្មែរបំភ្លេចចោល មិនស្វែងរកអ្នកធ្វើឃាតនិងអ្នកនៅពីក្រោយការធ្វើឃាតឡើយ ។៚

❄ ❄

❄